# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងធម្មការ និង សាសនា**

**លេខ ១៥៧ ក.ធ.សកស**

## សេចក្តីសំរេច

ស្តីពីការអនុញ្ញាតឱ្យកសាងវត្តថ្មីឈ្មោះថា " សាមគ្គីមុនីវ័ត្ត "
នៃគណៈមហានិកាយ ភូមិ គោកល្វៀង ឃុំព្រៃអង្គញ់ ស្រុកចន្ត្រា ខេត្តស្វាយរៀង

## រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី.

-បានឃើញព្រះរាជក្រមលេខ នស.រកម០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា.

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា.

-យោងតាមចំណារឯកភាពរបស់អភិបាល ខេត្ត ស្វាយរៀង លេខ ២៧ចប.សកិ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៩.

-យោងតាមចំណាររបស់ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តស្វាយរៀង លេខ ១៣១មធសខ.ស្វរចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០០១

-យោងតាមចំណាររបស់អភិបាលស្រុកចន្ត្រា លេខ ៣៩៥ចទ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨.

-តាមសំណើសុំរបស់ ពុទ្ធបរិស័ទវត្ត " សាមគ្គីមុនីវ័ត្ត " ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨.

## សំរេច

**ប្រការមួយ:** អនុញ្ញាតឱ្យកសាងវត្តថ្មី ឈ្មោះ " សាមគ្គីមុនីវ័ត្ត " នៃគណៈមហានិកាយ ដែលស្ថិតនៅក្នុងភូមិគោកល្វៀង ឃុំព្រៃអង្គញ់ ស្រុកចន្ត្រា ខេត្តស្វាយរៀង ដោយរក្សានូវក្បាច់រចនា ជាប្រពៃណីរបស់ជាតិ ។

**ប្រការពីរ :** វត្តថ្មីនេះ ត្រូវដាក់ប្រគេនព្រះសង្ឃ និងជូនពុទ្ធបរិស័ទគោរពប្រតិបត្តិ និងធ្វើបុណ្យទានឱ្យបានត្រឹមត្រូវ តាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត និងប្រពៃណីពុទ្ធសាសនា ព្រមទាំងច្បាប់របស់រដ្ឋឱ្យបានល្អប្រសើរ និងរីកចំរើន ។

**ប្រការបី :** ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្មការ និងសាសនា ខេត្តស្វាយរៀង អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងអាចារ្យ- គណៈកម្មការវត្ត ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែតុលា ឆ្នាំ ២០០២

ជា-សាវឿន

**ទទួលទ្វាយ-ជូន:**

-សម្តេចព្រះសង្ឃរាជគណៈមហានិកាយ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
" ដើម្បីថ្វាយ-ជូនជ្រាប "
-រាជកិច្ច " ដើម្បីចុះផ្សាយ "
-សាលាខេត្តស្វាយរៀង
-អភិបាលស្រុកចន្ត្រា
-ដូចប្រការបី
" ដើម្បីសហការអនុវត្ត "
ឯកសារ-កាលប្បវត្តិ